www.kidworship.kr

# ចំណងជើង៖ ចៀមដែលបាត់



56Page

**Narration** មានមនុស្សជាច្រើនបានចូលចិត្តរឿងដែលព្រះយេស៊ូ
បានមានព្រះបន្ទូលហើយពួកគេបានដើរតាមទ្រង់គ្រប់ទីកន្លែងដែលទ្រង់បានទៅ។
ប៉ុន្តែក៏មានមនុស្សជាច្រើនដែរ ដែលមិនចូលចិត្តព្រះយេស៊ូ។

**មនុស្សទី១** ព្រះយេស៊ូ ពិតជាចំឡែកណាស់!

**មនុស្សទី២** ខ្ញុំក៏យល់ថាអញ្ចឹងដែរ !!
ទ្រង់បានចេញទៅខាងក្រៅហើយបរិភោគជាមួយនឹងមនុស្សមានបាប..
វាពិតជាមិនត្រឹមត្រូវទេ!

**Narration** ហើយពេលនោះព្រះយេស៊ូក៏បាននិយាយរឿងមួយទៀតប្រាប់ទៅកាន់អ្នកទាំងអស់នោះ!!

---



57Page

**Narration** ជាយូរណាស់មកហើយមានអ្នកគង្វាលម្នាក់មានចៀមមួយរយក្បាល។
អ្នកគង្វាលគាត់ពិតជាស្រឡាញ់នឹងមើលថែរក្សាចៀមរបស់គាត់បានល្អណាស់។
ជារៀងរាល់ថ្ងៃនៅពេលដែលគាត់ឃ្វាលចៀមរបស់គាត់ពីវាលស្មៅមកកាន់ក្រោលនៅឯផ្ទះវិញ គឺគាត់តែងតែរាប់ចៀមរបស់គាត់។

**អ្នកគង្វាល** មើល៏!!
រាប់មើល៏..មួយ..ពីរ..បី…ម្ភៃ…សាមសិប….សែសិប…កៅសិបប្រាំពីរ..កៅសិបប្រាំបី..
កៅសិបប្រាំបួន…អូ? ចាំតិច!!
ខ្ញុំរាប់ម្តងទៀតមើល៏…មួយ..ពីរ..បី….កៅសិបប្រាំពីរ..កៅសិបប្រាំបី..កៅសិបប្រាំបួន…
ហ៊ឹម!! ប្រហែលជាខ្ញុំរាប់រំលងមួយហើយ!!

**Narration** ទោះបីជាគាត់ខំរាប់ជាច្រើនដងយ៉ាងណាក៏ដោយ ក៏ចៀមរបស់គាត់មានតែចំនួន
កៅសិបប្រាំបួនដដែល។

**អ្នកគង្វាល** ហ៊ឹម? តើចៀមទីមួយរយនៅឯណា?

**Narration** អ្នកគង្វាលគាត់ពិតជាមានការព្រួយបារម្ភចំពោះចៀមដែលគាត់បានបាត់នោះខ្លាំងណាស់។ គាត់បានចេញទៅគ្រប់ទីកន្លែងដើម្បីស្វែងរកចៀមរបស់គាត់ដែលបាត់នោះ។

---



58Page

**Narration** យប់ក៏កាន់តែជ្រៅ អ្នកគង្វាលមានអារម្មណ៍កាន់តែជ្រួលច្របល់
ក្នុងការស្វែងរកចៀមរបស់គាត់។
ប៉ុន្តែគាត់មិនបានបោះបង់ចោលចៀមរបស់គាត់នោះឡើយ
ហើយគាត់នៅតែបន្តស្វែងរកចៀមរបស់គាត់ដែលបានបាត់នោះ
ខណៈនោះគាត់បានឮសំឡេងចៀមរបស់គាត់បានស្រែក។

**ចៀមដែលបាត់** បេ៊…..បេ៊…..

**Narration** អ្នកគង្វាលក៏បានរត់សំដៅទៅកាន់សំឡេងនោះ!
គាត់ក៏បានឃើញចៀមរបស់គាត់ដែលបាត់នោះ បានជាប់ទើរនៅនឹងគែមច្រាំងជំរះថ្ម
ចៀមដ៏កំសត់ទទឹកខ្លួនជោគហើយញ័រខ្លួនដោយភាពភ័យខ្លាច។



59Page

**អ្នកគង្វាល** គឺពិតជាឯងមែន!!!តើឯងភ័យខ្លាំងណាស់មែនទេ! កុំខ្លាចអី ខ្ញុំនៅទីនេះ
ខ្ញុំមកជួយឯងហើយ!! អាហ្វូ...អាហ្វូ...

**Narration** អ្នកគង្វាលបានជួយសង្គ្រោះចៀមរបស់គាត់។
គាត់ពិតជាមានភាពសប្បាយរីករាយណាស់ ហើយគាត់បានដាក់ចៀមនៅលើស្មារបស់គាត់
រួចក៏ត្រឡប់ទៅផ្ទះវិញ។

..........................................................................................................

**Narration** នៅពេលដែលអ្នកគង្វាលបានត្រឡប់មកដល់ផ្ទះវិញគាត់ពិតជាមានអំណរសប្បាយរីករាយណាស់ គាត់បានហៅប្រពន្ធនិងកូនៗរបស់គាត់មកខាងក្រៅ។

**ព្រះយេស៊ូ** ប្រសិនបើអ្នកបានបាត់ចៀមរបស់អ្នក ហើយអ្នកបានរកឃើញវាវិញ
តើអ្នកសប្បាយចិត្តទេ? ដូចគ្នានេះដែរ វាកាន់តែមានអំណររីករាយនៅឯស្ថានបរមសុខ
នៅពេលដែលមនុស្សមានបាបម្នាក់បានប្រែចិត្តគំនិត។
វាប្រសើរជាងមនុស្សសុចរិតកៅសិបប្រាំបួននាក់ ដែលមិនត្រូវការ ការប្រែចិត្តគំនិត
ប៉ុន្តែព្រះមិនចង់ឲ្យមាននរណាម្នាក់ត្រូវបាត់បង់ឡើយ។

**Narration** ព្រះយេស៊ូក៏បានមានព្រះបន្ទូលអំពីអ្នកគង្វាល
និងសត្វចៀមប្រាប់ទៅបណ្ដាជនបន្តទៀត។
អ្នកគង្វាលល្អតែងតែស្គាល់ចៀមរបស់គាត់ រីឯចៀមគាត់ក៏ស្គាល់សំឡេងរបស់គាត់ដែរ។
វានឹងដើរតាមសំឡេងរបស់ម្ចាស់វា
ប៉ុន្តែនៅពេលដែលចៀមបានរត់ចេញឆ្ងាយវាពិតជារឿងដែលចំឡែកមួយ។
អ្នកគង្វាលល្អមិនដែលបានបោះបង់ចោលចៀម
ហើយក៏មិនបណ្ដោយឲ្យសត្វសាហាវមកវាយប្រហារដល់ចៀមរបស់គាត់ដែរ។អ្នកគង្វាលល្អតែងតែការពារចៀមរបស់គាត់។
ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់បណ្ដាជនថា៖ ទ្រង់នឹងលះបង់ព្រះជន្មរបស់ទ្រង់
ដើម្បីការពារចៀមរបស់ទ្រង់ឲ្យមានសុវត្ថិភាព។



60Page